# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខណ្ឌកម្មវិធីសិក្សា
# អប់រំបំណិនជីវិត




នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

២០១៦

# បុព្វកថា

បណ្តាប្រទេសលើពិភពលោកតែងចាត់ទុកវិស័យអប់រំជាវិស័យសំខាន់មួយ ដែលជានាការបណ្តុះបណ្តាលធនធានមនុស្សដើម្បីបម្រើតម្រូវការរបស់សង្គម។ ដោយសារសង្គមអភិវឌ្ឍឥតឈប់ឈរ វិស័យអប់រំត្រូវបានកែទម្រង់គ្រប់ទិដ្ឋភាពឆ្ពោះទៅរកការកសាងសង្គមមួយប្រកបដោយពុទ្ធិ និងមានវិបុលភាព។ ការកសាងសង្គមមួយបែបនេះទាមទារឱ្យមានមនុស្សប្រកបដោយចំណេះដឹង ជំនាញ និងឥរិយាបថថ្លៃថ្នូរ ជាពិសេសសិស្សានុសិស្សដែលបាននិងកំពុងទទួលសេវាអប់រំនាពេលបច្ចុប្បន្ន ដែលសិស្សទាំងនោះនឹងក្លាយជាពលរដ្ឋឆ្នើមសម្រាប់អភិវឌ្ឍប្រទេសជាតិ។

មនុស្សគ្រប់គ្នាត្រូវការបំណិនជីវិត ជាពិសេសសិស្សមានវ័យ ១១ឆ្នាំ ដល់ ១៨ ឆ្នាំ ត្រូវបានគេចាត់ទុកថាជាវ័យមានការប្រែប្រួលរហ័ស ដែលត្រូវការបំណិនជាចាំបាច់សម្រាប់ដំណើរជីវិតឈានទៅរកភាពចាស់ទុំ ប្រឡូកក្នុងការងារ និងរៀបចំខ្លួនក្លាយជាពលរដ្ឋល្អក្នុងសង្គម ដែលចាត់ទុកថាជាធនធានមួយដ៏ប្រពៃនៃសង្គមអភិវឌ្ឍន៍។

គោលនយោបាយអប់រំបំណិនជីវិតបានតាក់តែងនិងអនុមតិឱ្យប្រើប្រាស់នាឆ្នាំ២០០៦ បានឱ្យនិយមន័យបំណិនជីវិតសម្រាប់សិស្សជាបំណិនបញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើសេចក្តីសម្រេចចិត្ត ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ការសេពគប់ ការដោះស្រាយបញ្ហា និងការគ្រប់គ្រងខ្លួនឯងដែលរួមចំណែកលើកកម្ពស់ជីវិតប្រកបដោយផលិតភាពនិងសុខុមាលភាព ដើម្បីជានាភាពជោគជ័យក្នុងការដោះស្រាយ បញ្ហាប្រឈមប្រចាំថ្ងៃ។ កម្មវិធីអប់រំបំណិនជីវិតមានគោលបំណងផ្តល់ឱកាសស្មើៗគ្នា ដល់អ្នកសិក្សាទាំងអស់ក្នុងការទទួលបានការសិក្សាផ្នែកចំណេះដឹង ជំនាញ និងឥរិយាបថវិជ្ជមាន សម្រាប់ចូលរួមលើកកម្ពស់ជីវភាពសង្គម។

ក្របខណ្ឌកម្មវិធីសិក្សាអប់រំបំណិនជីវិតនេះជាផែនទីចង្អុលផ្លូវក្នុងការអភិវឌ្ឍកម្មវិធីសិក្សាលម្អិត រៀបចំសៀវភៅសិក្សាគោលលើមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន និងកសាងសមត្ថភាពមន្ត្រីគ្រប់លំដាប់ថ្នាក់ ដែលបានកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា អង្គការជាតិ-អន្តរជាតិ អង្គភាពពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទាំងអស់ នឹងចូលរួមសហការនិងគាំទ្រការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាអប់រំបំណិនជីវិតឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីអភិវឌ្ឍបំណិនសម្បទាពលរដ្ឋ ជាពលរដ្ឋសកម្មនិងគុណតម្លៃផលិតភាពសម្រាប់វិបុលភាពជាតិ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

# មាតិកា


បុព្វកថា ..... 1

១. សេចក្តីផ្តើម ..... 1

២. បញ្ញត្តិនៃការអប់រំបំណិនជីវិត ..... 2

៣. គោលបំណង ..... 4

៤. កម្មវិធីសិក្សា ឬប្រធានបទសិក្សា ..... 4

៣.១ កម្មវិធីសិក្សាបំណិនជីវិតសម្រាប់បឋមសិក្សា ..... 5

៣.២ កម្មវិធីសិក្សាបំណិនជីវិតសម្រាប់មធ្យមសិក្សា ..... 6

៥. សមត្ថភាពរំពឹងទុក ..... 7

៦. គោលការណ៍នៃការបង្រៀន ..... 8

៦.១. គោលការណ៍នៃការបង្រៀន ..... 8

៦.២. លំនាំនៃការបង្រៀន និងរៀនបំណិនជីវិត ..... 8

៧. ការវាយតម្លៃការបង្រៀន និងរៀនបំណិនជីវិត ..... 9

៨. យន្តការគាំទ្រ និងអនុវត្តបំណិនជីវិត ..... 9

៨.១. ការពង្រឹងសមត្ថភាពមន្ត្រីអប់រំថ្នាក់ជាតិ ..... 9

៨.២. ការណែនាំសម្រាប់ការតម្រង់ទិសថ្នាក់ខេត្ត ..... 10

៨.៣. ការបំប៉នក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ( DTMT) និងគ្រូបំណិនជីវិត ..... 10

៨.៤. ការតម្រង់ទិសដល់សាលារៀន និងសហគមន៍ ..... 10

៨.៥. ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ..... 11

៨.៦. កិច្ចសហប្រតិបត្តិការ ..... 11

ឯកសារយោង ..... 12

ឯកសារដែលបានអភិវឌ្ឍ ..... 13

សទ្ទានុក្រម ..... 14

# ១. សេចក្តីផ្តើម

ការអប់រំបំណិនជីវិតគឺជាការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សិស្សដែលរស់នៅក្នុងយុគសម័យសកលភាវូបនីយកម្ម។ វាតម្រូវឱ្យពួកគេមានចំណេះដឹងជុំវិញខ្លួន បំណិន ជំនាញ និងឥរិយាបថសមស្រប ដើម្បីធានាថាពួកគេអាចដោះស្រាយរាល់ការប្រឈមនិងតម្រូវការក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។កម្មវិធីបំណិនជីវិតត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡាតាមគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៥-២០០៩។ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយអប់រំបំណិនជីវិតនាឆ្នាំ ២០០៦ ដោយបានកំណត់និយមន័យបំណិនជីវិតគឺ៖ *"ជាបំណិនបញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចដោះស្រាយនិងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។*

ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេសនាឆ្នាំ ២០១៥ ដែលបានផ្តោតលើសមត្ថភាពរបស់សិស្សខាងអក្ខរសាស្រ្តនិងលេខសាស្រ្ត ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បំណិនប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម បំណិនពិចារណានិងការបង្កើតថ្មី បំណិនអនុវត្តចំណេះដឹងនិងជំនាញ បំណិនអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម និងបំណិនសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ។ ក្នុងសមត្ថភាពទាំងនេះ ការអប់រំបំណិនជីវិតបានរួមចំណែកយ៉ាងច្រើនក្នុងការសម្រេចបាននូវសមត្ថភាពទាំងនោះ។

ការអប់រំបំណិនជីវិតត្រូវបានទទួលស្គាល់ថា ជាតម្រូវការចាំបាច់សម្រាប់អភិវឌ្ឍបុគ្គលិកលក្ខណៈអ្នកសិក្សា។ សិស្សត្រូវបានបង្រៀនឱ្យមានលក្ខណៈសម្បត្តិពេញលេញស្របតាមតម្រូវការរបស់ខ្លួន និងសង្គម។ គោលនយោបាយអប់រំបំណិនជីវិតបានកំណត់ថា បំណិនជីវិតមានពីរប្រភេទគឺបំណិនមូលដ្ឋាន និងបំណិនអាជីព៖

**បំណិនមូលដ្ឋាន**

បំណិនមូលដ្ឋានជាបំណិនចាំបាច់ដែលអ្នកសិក្សាគ្រប់រូបត្រូវតែទទួលបាន ដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ការរស់នៅ ហើយត្រូវបានបញ្ជ្រាបចូលតាមមុខវិជ្ជាសំខាន់ៗបួន (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្រ្ត និងសិក្សាសង្គម) ដែលជាកម្មវិធីសិក្សាគោលរបស់ជាតិ។ បំណិនមូលដ្ឋាន ចែកចេញជាពីរផ្នែកតូចៗទៀតគឺ **បំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជាជីវៈ**។ បំណិនជីវិតទូទៅជារួមផ្តោតលើខ្លឹមសារសុខភាពផ្ទាល់ខ្លួន សុវត្ថិភាព ការធ្វើផែនការជីវិតប្រចាំថ្ងៃ និងការអភិវឌ្ឍផ្នែកសីលធម៌។ បំណិនបុរេវិជ្ជាជីវៈជាបំណិនទន់ផ្តោតលើការត្រៀមចាប់យកអាជីពណាមួយនៅពេលអនាគត។

**បំណិនអាជីព**

បំណិនអាជីពជាបំណិនទាំងឡាយណា ដែលផ្តោតលើសមត្ថភាពវិជ្ជាជីវៈជាក់ស្តែង ហើយចែកចេញជាពីរផ្នែកតូចៗទៀតគឺ **បំណិនអាជីពងាយៗ និងបំណិនវិជ្ជាជីវៈ**។ បំណិនអាជីពងាយបង្រៀននៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានពីថ្នាក់ទី ៤ ដល់ទី ១០ ហើយបំណិនវិជ្ជាជីវៈបង្រៀននៅក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើសសម្រាប់ថ្នាក់ទី១១ និង ១២ និងការអប់រំបច្ចេកទេស។

កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន មានគោលបំណងផ្តល់ឱកាសដល់សិស្សដើម្បីពង្រីកការសិក្សារបស់ពួកគេដោយផ្អែកទៅលើតម្រូវការតាមមូលដ្ឋាន និងចំណាប់អារម្មណ៍របស់បុគ្គលម្នាក់ៗ។ វាជាមុខវិជ្ជាមួយនៃកម្មវិធីសិក្សាជាតិដែលបានកំណត់នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស ដោយផ្តល់ម៉ោងសិក្សា ២ ម៉ោងក្នុងមួយសប្តាហ៍។ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់កម្មវិធីសិក្សាជាក់លាក់សម្រាប់កម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលជាគោលការណ៍ ក្រសួងតម្រូវឱ្យសាលារៀនរៀបចំកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដោយខ្លួនឯង

ដើម្បីលើកកម្ពស់ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត តម្រង់ទិសវិជ្ជាជីវៈ និងអភិវឌ្ឍអាជីពងាយ។ ក្នុងការអនុវត្តជាក់ស្តែង សាលារៀនជួបការលំបាកជាច្រើន ហើយសមត្ថភាពរបស់ពួកគេនៅមានកម្រិតក្នុងការអនុវត្តគោលនយោបាយនេះ។ ការប្រឈមទាំងនេះរួមមាន៖ កង្វះគ្រូ ថវិកា គ្រូឯកទេស ការចូលរួមរបស់សហគមន៍ និងសមត្ថភាពរបស់សាលារៀននៅមានកម្រិតក្នុងការរៀបចំកម្មវិធីបំណិនជីវិតនេះ។

ក្របខណ្ឌកម្មវិធីសិក្សាបំណិនជីវិតបានរៀបចំឡើងដោយប្រមូលផ្តុំនូវគំនិត ទស្សនៈ ព្រមទាំងដំណើរការអប់រំបំណិនជីវិត ដោយផ្តោតលើការអភិវឌ្ឍចំណេះដឹងក្នុងសហគមន៍ បំណិន គុណតម្លៃ និងឥរិយាបថរបស់សិស្ស។ ក្នុងក្របខណ្ឌនេះ បំណិនមូលដ្ឋាននិងបំណិនអាជីពត្រូវបានពិនិត្យនិងរៀបចំឡើងវិញ ដោយចែកជាផ្នែករងបីដែលនៅក្នុងគោលនយោបាយមានតែពីរប៉ុណ្ណោះ។ ក្នុងន័យនេះ វាកំណត់ពីចង្កោមបំណិនខុសៗគ្នា ដែលតម្រូវឱ្យសិស្សមាន ដើម្បីអាចដោះស្រាយបញ្ហា និងការប្រឈមក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ឯកសារនេះផ្តោតទៅលើតម្រូវការនៃការអភិវឌ្ឍបំណិនមូលដ្ឋាន និងបំណិនអាជីព នៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលគោលនយោបាយផ្តោតតែទៅលើបំណិនអាជីពងាយតែប៉ុណ្ណោះ ដោយគិតថាបំណិនមូលដ្ឋានត្រូវបានបញ្ជ្រាបចូលទៅក្នុងមុខវិជ្ជាគោលនៃកម្មវិធីសិក្សាជាតិរួចហើយ។

## ២. បញ្ញត្តិនៃការអប់រំបំណិនជីវិត

បញ្ញត្តិនៃការអប់រំបំណិនជីវិតថ្មីមួយ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើអនុសាសន៍នៃការពិនិត្យឡើងវិញវិស័យអប់រំ និងសន្និបាតអប់រំឆ្នាំ ២០១៥។ ដ្យាក្រាមខាងក្រោមបង្ហាញពីបញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត៖




បញ្ញត្តិបំណិនជីវិតត្រូវបានយកទៅអនុវត្តទៅតាមគំរូខុសគ្នាបីគឺ៖ ទី១. ការបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សាជាតិ ទី២. កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងទី៣. កម្មវិធីបំណិនជីវិតដែលអនុវត្តជាក់លាក់ដោយដៃគូអភិវឌ្ឍន៍។ ទោះជាតាមគំរូណាក៏ដោយ សិស្សអភិវឌ្ឍបំណិនតាមរយៈការឆ្លុះបញ្ចាំង និងវិភាគលើការរៀនមេរៀនបំណិនជីវិតទាំងនោះរួម

មាន៖ ចំណេះដឹងទូទៅជុំវិញសហគមន៍របស់ខ្លួន បំណិនបុរេវិជ្ជាជីវៈ គុណតម្លៃផ្ទាល់ខ្លួន ការគ្រប់គ្រងអាជីវកម្ម និងការងារ និងជំនាញបច្ចេកទេស ស្របទៅតាមតម្រូវការក្នុងតំបន់។

**ក្របខណ្ឌបំណិនដែលសិស្សត្រូវអភិវឌ្ឍ**

| បំណិនមូលដ្ឋាន | | បំណិនអាជីព | |
|---|---|---|---|
| ចំណេះដឹងទូទៅ | ខ្លឹមសារជាក់លាក់ដែលជួយសិស្សសម្រេចចិត្តបានត្រឹមត្រូវដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយដូចជា៖<br>• អំណាន និងការគណនា<br>• អនាម័យ និងជំងឺឆ្លង<br>• ការយល់ដឹងពីបរិស្ថានជុំវិញខ្លួន<br>• ដំណើរការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន<br>• ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច<br>• និន្នាការពិភពលោក ។ល។ | បំណិនមូលដ្ឋាន | បំណិននេះសិស្សរៀននៅក្នុងកម្មវិធីសិក្សា និងបំណិនជីវិតតាមមូលដ្ឋានដូចបានកំណត់ក្នុងដ្យាក្រាមខាងលើ៖<br>• ចំណេះដឹងទូទៅ<br>• បំណិនបុរេវិជ្ជាជីវៈ<br>• គុណតម្លៃផ្ទាល់ខ្លួន |
| បំណិនបុរេវិជ្ជាជីវៈឬបំណិនការងារ | ចង្កោមបំណិនមួយចំនួនដែលជួយឱ្យជីវិត និងការងាររបស់សិស្សទទួលបានជោគជ័យដូចជា៖<br>• ការគិតបែបពិចារណា<br>• ការគិតដោយច្នៃប្រឌិត<br>• ការដោះស្រាយបញ្ហា<br>• ការសម្រេចចិត្ត<br>• ការប្រាស្រ័យទាក់ទង<br>• ការកំណត់គោលដៅ<br>• ការធ្វើផែនការអនាគត<br>• ការហ៊ានប្រថុយ<br>• ការមានហេតុផល<br>• ការងារជាក្រុម ។ល។ | បំណិនសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ | ចង្កោមបំណិនដែលជួយសិស្សក្នុងការងារ និងធ្វើអាជីវកម្មទទួលបានជោគជ័យ ដូចជា៖<br>• ការធ្វើផែនការនិងចាត់ចែង<br>• ការគ្រប់គ្រងពេលវេលា<br>• ការគ្រប់គ្រងថវិកា<br>• ការស្វែងរកទីផ្សារ<br>• ភាពជាសហគ្រិន<br>• ការស្វែងរកការងារ<br>• បច្ចេកទេសសម្ភាស<br>• ពិភពការងារ<br>• ការហ្វឹកហាត់ការងារ។ល។ |
| គុណតម្លៃផ្ទាល់ខ្លួន | ចង្កោមតម្លៃមួយចំនួនដែលជួយឱ្យសិស្សទទួលបាន នូវសេចក្ដីថ្លៃថ្នូរនិងការគោរពដូចជា៖<br>• ការឱ្យតម្លៃខ្លួនឯង<br>• ការគ្រប់គ្រងកំហឹង<br>• ភាពស្មោះត្រង់<br>• ការទទួលខុសត្រូវ<br>• ភាពយុត្តិធម៌<br>• ការមានអធ្យាស្រ័យល្អ<br>• ឥរិយាបថវិជ្ជមាន<br>• ការយល់ចិត្តគ្នា។ល។ | បំណិនបច្ចេកទេស | ចង្កោមបំណិនមួយចំនួនដែលពាក់ព័ន្ធទៅនឹងបច្ចេកទេសក្នុងការប្រត្តិបត្តិអាជីពដូចជា៖<br>• បច្ចេកទេសការងារទទួលភ្ញៀវ<br>• បច្ចេកទេសសំអាងការ<br>• បច្ចេកទេសចុងភៅ<br>• បច្ចេកទេសចិញ្ចឹមសត្វ<br>• បច្ចេកទេសដាំដំណាំ<br>• បច្ចេកទេសកាត់ដេរ<br>• បច្ចេកទេសជួសជុលកង់ ម៉ូតូ<br>• បច្ចេកទេសជាងកំបោរ<br>• បច្ចេកទេសឧស្សាហកម្ម។ល។ |

## ៣. គោលបំណង

ការអប់រំបំណិនជីវិតមានគោលបំណងលើកកម្ពស់ការផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្ត ដោយជំរុញឲ្យសិស្សស្វែងយល់ពីបញ្ហាងាយៗដែលមាននៅជុំវិញខ្លួន ប្រើប្រាស់ចំណេះដឹងដែលគេមាន ដើម្បីដោះស្រាយដោយមានការសហការពីភាគីពាក់ព័ន្ធ។ លើសពីនេះទៀត សិស្សអាចរៀនពីអាជីពងាយៗដែលមាននៅតាមសហគមន៍ តាមរយៈការចែករំលែកចំណេះដឹងរបស់មន្ត្រីជំនាញ កសិករ និងអាជីវករនៅក្នុងមូលដ្ឋាន។ ការរៀនពីបញ្ហាសង្គម និងអាជីវកម្មដែលមានលក្ខណៈជាការសិក្សាស្រាវជ្រាវ វិភាគ រកដំណោះស្រាយ ព្រមទាំងកែលម្អ និងបង្កើតថ្មី ជំរុញឲ្យសិស្សមានការអភិវឌ្ឍបំណិនដូចខាងក្រោម៖

**១. លើកកម្ពស់ការអប់រំបំណិនបញ្ញា** ឱ្យមានសមត្ថភាពក្នុងការគិតពិចារណារ ថ្លឹងថ្លែង ការច្នៃប្រឌិត នវានុវត្តន៍ ការវិភាគនិងការដោះស្រាយបញ្ហា ការធ្វើផែនការអនាគត និងការធ្វើការសម្រេចចិត្តស្របតាមការវិវឌ្ឍនានាក្នុងមូលដ្ឋាន តំបន់ និងសកលលោក ដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួន គ្រួសារ និងសង្គម។

**២. លើកកម្ពស់ការអប់រំបំណិនផ្លូវចិត្ត** ឱ្យមានស្មារតីចូលចិត្ត ស្រឡាញ់ ទទួលខុសត្រូវ ស្វែងយល់និងឱ្យតម្លៃដល់អ្នកដទៃ ដល់អរិយធម៌ វប្បធម៌ផ្សេងៗ ប្រវត្តិសាស្ត្រនានាដែលអាចឈានទៅរកការកសាងស្មារតីសាធារណៈ ក្នុងន័យចេះគោរពសិទ្ធិអ្នកដទៃនិងមានសីលធម៌ ចេះថែរក្សា និងលើកស្ទួយតម្លៃជាតិ មានស្មារតីស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រ យល់ដឹងសារសំខាន់ និងចេះការពារ ថែរក្សាបរិស្ថានធម្មជាតិ សង្គម និងវប្បធម៌។ មានឥរិយាបថវិជ្ជមានចំពោះការងារ និងមានសមត្ថភាពធ្វើការជាមួយអ្នកដ៏ទៃប្រកបដោយប្រសិទ្ធភាព និងភាពសុខដុមមានការកោតសរសើរនិងឱ្យតម្លៃសារសំខាន់នៃគំនិតវិទ្យាសាស្ត្រ បច្ចេកវិទ្យា បង្កើតថ្មី និង ច្នៃប្រឌិត។

**៣. បង្កើនការអប់រំបំណិនទង្វើ** ឱ្យក្លាយជាពលរដ្ឋសកម្មមានសមត្ថភាពគ្រប់គ្រង ផលិត បង្កើតថ្មី ទទួលខុសត្រូវលើសកម្មភាព លើសេចក្តីសម្រេចរបស់ខ្លួន ស្មារតីសាធារណៈ គុណភាពផលិត និងមានជំនឿជាក់ខ្លួនឯង។

**៤. លើកកម្ពស់ការអប់រំបំណិនសុខភាព** ក្នុងការថែរក្សាសុខភាពផ្នែកផ្លូវកាយ បញ្ញា ស្មារតីរបស់ខ្លួន ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយការថែរក្សាសុខភាពផ្ទាល់ខ្លួន គ្រួសារ និងសង្គមឱ្យកាន់តែល្អប្រសើរសម្រាប់អភិវឌ្ឍ។

## ៤. កម្មវិធីសិក្សា ឬប្រធានបទសិក្សា

បំណែងចែកម៉ោងសិក្សា

| **កម្រិតបឋមសិក្សា (ថ្នាក់ទី៤-៦)** | | |
|---|---|---|
| **ប្រធានបទសិក្សា** | **ចំនួនម៉ោងក្នុង១សប្តាហ៍** | **ចំនួនសប្តាហ៍** |
| បំណិនបច្ចេកទេស (ផ្នែកកសិកម្ម ផ្នែកសិប្បកម្មខ្នាតតូច ផ្នែកសេវាកម្ម) | ១ម៉ | ៣៥ |
| បំណិនសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ | ១ម៉ | ៣៥ |
| **កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩)** | | |
| បំណិនបច្ចេកទេស (ផ្នែកកសិកម្ម ផ្នែកសិប្បកម្មខ្នាតតូច ផ្នែកសេវាកម្ម) | ១ម៉ | ៣៥ |
| បំណិនសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ | ១ម៉ | ៣៥ |

(១ ម៉ោងសិក្សា មានរយៈពេល ៤០ នាទីសម្រាប់បឋមសិក្សា និង ៥០ នាទី សម្រាប់មធ្យមសិក្សា)

## ៣.១ កម្មវិធីសិក្សាបំណិនជីវិតសម្រាប់បឋមសិក្សា

កម្រិតបឋមសិក្សាៈ បង្រៀន ២ម៉ោង (១ម៉ោងសិក្សា មានរយៈពេល ៤០ នាទី) ក្នុង១សប្តាហ៍ តាមខ្លឹមសារដូចជាៈ

| ខ្លឹមសារ | | កម្រិតថ្នាក់ | ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំ | |
|---|---|---|---|---|
| | | | ទ្រឹស្តី | ប្រតិបត្តិ |
| **បំណិនមូលដ្ឋាន** | ចំណេះដឹងទូទៅ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនការងារ និងគុណតម្លៃផ្ទាល់ខ្លួន | ថ្នាក់ទី១-៦ | តាមមុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ ភាសាខ្មែរ និងសិក្សាសង្គម | - កិច្ចការផ្ទះ<br>- កិច្ចការគម្រោង |
| **បំណិនសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ** | - គ្រប់គ្រងអាជីវកម្ម សេដ្ឋកិច្ច និងការងារ ការសិក្សាទីផ្សារ និងកំណត់ត្រាចំណូលចំណាយ។<br>- ការប្រាស្រ័យទាក់ទង ការងារក្រុម ការធ្វើផែនការ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ស្វ័យគ្រប់គ្រង ។ល។ | ថ្នាក់ទី៤-៦ | ថ្នាក់ទី៤ ៣៥ម៉<br>ថ្នាក់ទី៥ ៣៥ម៉<br>ថ្នាក់ទី៦ ៣៥ម៉ | -ការងារក្រុម<br>-អនុវត្តគម្រោង |
| **បំណិនបច្ចេកទេស** | **ផ្នែកកសិកម្មៈ**<br>**ដំណាំផ្លែ** (ត្រប់ ត្រសក់ ល្ពៅ ល្ហុង ម្ទេសហាវ៉ៃ ម្រះ ពោត សណ្តែកបាយ ឪឡឹក សណ្តែកកួរ សណ្តែកបារាំង ត្រឡាច ប៉េងប៉ោះ ននោង)។<br>**ដំណាំដើមនិងស្លឹក** (ត្រកួន ខ្ទឹមស្លឹក ស្ពៃក្រញាញ់ ស្ពៃចង្កឹះ អំពៅ ស្ពៃខៀវ ស្ពៃជើងទា ផ្កា សណ្តែកបណ្តុះ ខាត់ណា ផ្សិតចំបើង ការបណ្តុះកូនឈើ សាលាដ ស្ពៃក្តោប ស្ពៃផ្កា)។<br>**ដំណាំមើម** (ដំឡូងជ្វា ឆៃថាវ ដំឡូងមី ខ្ទឹមបារាំង ខ្ទឹមក្រហម)។<br>**ការចិញ្ចឹមសត្វ** (មាន់ ត្រី ជន្លេន ទា ជ្រូក ទន្សាយ គោ ពពែ កង្កែប អន្ទង់ ក្រួច)។ | ថ្នាក់ទី៤-៦ | ថ្នាក់ទី៤ ១៥ម៉<br>ថ្នាក់ទី៥ ១៥ម៉<br>ថ្នាក់ទី៦ ១៥ម៉ | -ការងារក្រុម<br>-អនុវត្តគម្រោង |
| | **ផ្នែកសិប្បកម្មខ្នាតតូច** រួមមាន ការធ្វើអំបោស ទឹកខ្មេះធ្វើពីទឹកដូងឬទឹកត្នោត បត់ក្រដាសបង្កើតជារូបភាព | ថ្នាក់ទី៤-៦ | ថ្នាក់ទី៤ ១០ម៉<br>ថ្នាក់ទី៥ ១០ម៉<br>ថ្នាក់ទី៦ ១០ម៉ | -ការងារក្រុម<br>-អនុវត្តគម្រោង<br>-អនុវត្តពេងជាង |

| | | | | |
|---|---|---|---|---|
| | ផ្សេងៗ បត់ក្រដាសធ្វើស្រោមសំបុត្រ ការធ្វើវត្ថុអនុស្សាវរីយ៍ពីវត្ថុផ្សេងៗ (សំបកស៊ុត សំបកខ្យង ខ្លៅ ឬស្លឹកត្នោត វល្លិ រំពាក់) ត្បាញក្រដាសពណ៌ ផលិតប្រអប់ដាក់វត្ថុអនុស្សាវរីយ៍ ការផលិតបង្កី ជើងម៉ា ស្នូក មួកស្លឹកត្នោត ទ្រនាប់កែវនិងចាន និងការផលិតទូពីផ្តៅ។ | | | |
| | **ផ្នែកសេវាកម្ម:** រួមមាន ការរៀបចំសណ្តាប់ធ្នាប់ក្នុងគេហដ្ឋាននិងថ្នាក់រៀន ការបង្ហាញផ្លូវភ្ញៀវ ដំណាប់ចេក ការរៀបចំផ្កាដាក់ថូឬកន្ត្រក ការលក់នំ បដិសណ្ឋារកិច្ចចំពោះភ្ញៀវ ជ្រក់សណ្តែកបណ្តុះ ជ្រក់ត្រសក់ ចំណីឬសម្ភារផ្សេងៗ ការខាត់ស្បែកជើងឬបត់សម្លៀកបំពាក់ ការលក់វត្ថុអនុស្សាវរីយ៍ ការក្រងភួងផ្កាម្លិះ ដំណាប់អំពិលទុំ ត្រីងៀត ការរ៉េម ។ | ថ្នាក់ទី៤-៦ | ថ្នាក់ទី៤ ១០ម៉<br>ថ្នាក់ទី៥ ១០ម៉<br>ថ្នាក់ទី៦ ១០ម៉ | -ការងារក្រុម<br>-អនុវត្តគម្រោង |

## ៣.២ កម្មវិធីសិក្សាបំណិនជីវិតសម្រាប់មធ្យមសិក្សា

កម្រិតមធ្យមសិក្សា: បង្រៀន ២ម៉ោង (១ ម៉ោងសិក្សាមានរយៈពេល ៥០ នាទី)ក្នុង១សប្តាហ៍ តាមខ្លឹមសារដូចជា៖

| **ខ្លឹមសារ** | | **កម្រិតថ្នាក់** | **ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំ** | |
|---|---|---|---|---|
| | | | **ទ្រឹស្តី** | **ប្រតិបត្តិ** |
| **បំណិនមូលដ្ឋាន** | ចំណេះដឹងទូទៅ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនការងារ និងគុណតម្លៃផ្ទាល់ខ្លួន | ថ្នាក់ទី៧-៩ | មុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ ភាសាខ្មែរ និងសិក្សាសង្គម | - កិច្ចការផ្ទះ<br>-កិច្ចការគម្រោង |
| **បំណិនសហគ្រិនភាព និងភាពជាអ្នកដឹកនាំ** | - ការគ្រប់គ្រងអាជីវកម្ម សេដ្ឋកិច្ច និងការងារ<br>- ការប្រាស្រ័យទាក់ទង ការងារក្រុម ការធ្វើផែនការ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ស្វ័យគ្រប់គ្រង ។ល។ | ថ្នាក់ទី៧-៩ | ថ្នាក់ទី៧ ៣៥ម៉<br>ថ្នាក់ទី៨ ៣៥ម៉<br>ថ្នាក់ទី៩ ៣៥ម៉ | -សំដែងតួ<br>-កិច្ចការគម្រោង |
| **បំណិនបច្ចេកទេស** | **ផ្នែកកសិកម្ម:** រួមមានមូលដ្ឋានគ្រឹះ | ថ្នាក់ទី៧-៩ | ថ្នាក់ទី៧ ១៥ម៉ | -ការងារក្រុម |

| | | | | |
|---|---|---|---|---|
| | បច្ចេកទេសកសិកម្ម ការបណ្ដុះកូនរុក្ខជាតិ ដំណាំផ្លែ ដំណាំដើមនិងស្លឹក ដំណាំមើម ការចិញ្ចឹមសត្វលើគោក និងការចិញ្ចឹមសត្វក្នុងទឹក ។ល។ | | ថ្នាក់ទី៨ ១៥ម៉<br>ថ្នាក់ទី៩ ១៥ម៉ | -អនុវត្តគម្រោង |
| | **ផ្នែកសិប្បកម្មខ្នាតតូច:** រួមមាន តម្បាញ វត្ថុអនុស្សាវរីយ៍ និងជំនាងឈើ ។ | ថ្នាក់ទី៧-៩ | ថ្នាក់ទី៧ ១០ម៉<br>ថ្នាក់ទី៨ ១០ម៉<br>ថ្នាក់ទី៩ ១០ម៉ | -អនុវត្តគម្រោង<br>-អនុវត្តរោងជាង |
| | **ផ្នែកសេវាកម្ម:** រួមមានតំណាប់ ជ្រក់ មុខម្ហូបខ មុខម្ហូបញាំ មុខម្ហូបភ្លា មុខម្ហូបឆា មុខម្ហូបអាំង មុខម្ហូបបំពង សម្ល ស៊ុប បង្អែម ភេសជ្ជៈ ។ | ថ្នាក់ទី៧-៩ | ថ្នាក់ទី៧ ១០ម៉<br>ថ្នាក់ទី៨ ១០ម៉<br>ថ្នាក់ទី៩ ១០ម៉ | -ធ្វើម្ហូប<br>-ការងារក្រុម<br>-អនុវត្តគម្រោង |

(សាលារៀនអាចកំណត់ជ្រើសរើសបំណិនណាមួយ ឬទាំងអស់តាមចំនួនម៉ោងកំណត់នៃកម្មវិធីសិក្សាជាតិ ២ម៉ោងក្នុង ១សប្ដាហ៍ ឬ៧០ម៉ោងក្នុង១ឆ្នាំសិក្សា)

## ៥. សមត្ថភាពរំពឹងទុក

| បំណិនដែលសិស្សគួរអភិវឌ្ឍតាមកម្រិតថ្នាក់បឋមសិក្សា | | |
|---|---|---|
| **ថ្នាក់ទី ៤** | **ថ្នាក់ទី ៥** | **ថ្នាក់ទី ៦** |
| • ការអាន សរសេរ និងនព្វន្ត<br>• ការគិតនិងដោះស្រាយ<br>• ការគ្រប់គ្រងពេលវេលា<br>• ការប្រាស្រ័យទាក់ទង<br>• ការងារក្រុម<br>• ភាពស្មោះត្រង់<br>• អនាម័យនិងសុខភាព<br>• ការស្គាល់គ្រោះមហន្តរាយ គ្រោះធម្មជាតិ និងបរិស្ថាន<br>• សញ្ញាណបច្ចេកទេស | • អក្ខរសាស្ត្រនិងលេខសាស្ត្រ<br>• ការគិតបែបពិចារណា<br>• ការកំណត់គោលដៅរយៈពេលខ្លី<br>• ការដោះស្រាយបញ្ហា<br>• ក្ដីអាណិតអាសូរ<br>• ការយល់ចិត្តគ្នា<br>• ឥរិយាបថវិជ្ជមាន<br>• ការទទួលខុសត្រូវ<br>• អនាម័យនិងសុខភាព<br>• ការស្គាល់គ្រោះមហន្តរាយ គ្រោះធម្មជាតិ និងបរិស្ថាន<br>• សញ្ញាណបច្ចេកទេស | • អក្ខរសាស្ត្រនិងលេខសាស្ត្រ<br>• ការធ្វើផែនការរៀន<br>• ការទទួលខុសត្រូវតាមសិទ្ធិ<br>• ការមានហេតុផល<br>• ការសម្រេចចិត្ត<br>• ស្គាល់ពីមុខរបរឬការងារ<br>• ឥរិយាបថវិជ្ជមាន<br>• ការងារក្រុម<br>• អនាម័យនិងសុខភាព<br>• សញ្ញាណអាជីវកម្ម ការងារ<br>• ការស្គាល់គ្រោះមហន្តរាយ គ្រោះធម្មជាតិ និងបរិស្ថាន<br>• សញ្ញាណបច្ចេកទេស |

| បំណិនដែលសិស្សគួរអភិវឌ្ឍតាមកម្រិតថ្នាក់មធ្យមសិក្សាបឋមភូមិ | | |
|---|---|---|
| **ថ្នាក់ទី ៧** | **ថ្នាក់ទី ៨** | **ថ្នាក់ទី ៩** |
| • អក្ខរសាស្ត្រនិងលេខសាស្ត្រ<br>• ការគ្រប់គ្រងពេលវេលា<br>• ការប្រាស្រ័យទាក់ទង | • អក្ខរសាស្ត្រនិងលេខសាស្ត្រ<br>• ការគិតបែបពិចារណា<br>• ការកំណត់គោលដៅ | • អក្ខរសាស្ត្រនិងលេខសាស្ត្រ<br>• ការធ្វើផែនការនិងចាត់ចែង<br>• ការមានហេតុផល |

| | | |
|---|---|---|
| • ការងារក្រុម<br>• ភាពស្មោះត្រង់<br>• ការឱ្យតម្លៃខ្លួនឯង<br>• សញ្ញាណអាជីវកម្មនិងការងារ<br>• មូលដ្ឋានគ្រឹះបច្ចេកទេស | • ការដោះស្រាយបញ្ហា<br>• ការយល់ចិត្តគ្នា<br>• ការទទួលខុសត្រូវ<br>• សញ្ញាណអាជីវកម្មនិងការងារ<br>• មូលដ្ឋានគ្រឹះបច្ចេកទេស | • ការសម្រេចចិត្ត<br>• ឥរិយាបថវិជ្ជមាន<br>• ការគ្រប់គ្រងកំហឹង<br>• សញ្ញាណអាជីវកម្មនិងការងារ<br>• មូលដ្ឋានគ្រឹះបច្ចេកទេស |

**សម្គាល់៖** សមត្ថភាពរឹងទុកទាំងនេះ ត្រូវដាក់បញ្ចូលទៅក្នុងសៀវភៅតាមដានការសិក្សារបស់សិស្ស ដើម្បីឲ្យគ្រូនិងសិស្សតាមដានការអភិវឌ្ឍបំណិនរបស់គេរៀងៗខ្លួន។

# ៦. គោលការណ៍នៃការបង្រៀន

## ៦.១. គោលការណ៍នៃការបង្រៀន

១.១. ការបង្រៀនគឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដោយប្រើប្រាស់វិធីសាស្ត្រគោលវិធីសិស្សមជ្ឈមណ្ឌល ឬវិធីសាស្ត្រចម្រុះ។

១.២. ការបង្រៀនគឺជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្សឱ្យចេះរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាពនិងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹង សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃដោយប្រើប្រាស់វិធីសាស្ត្រទំនើបដូចជា សហការ អង្កេត គម្រោង។

១.៣. ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សា។

១.៤. ការបង្រៀនត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រនិងសម្ភារឧបទេស រួមទាំងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្បូរបែបនិងមានបច្ចុប្បន្នភាព។

## ៦.២. លំនាំនៃការបង្រៀន និងរៀនបំណិនជីវិត

លំនាំនៃការបង្រៀននិងរៀនបំណិនជីវិតមានលក្ខណៈជាការងារគម្រោង ការសិក្សាស្រាវជ្រាវងាយៗ និងផ្តួចផ្តើមដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគេ ដោយចែករំលែកបទពិសោធនិងចំណេះដឹងទៅវិញទៅមក។ ទន្ទឹមនឹងនេះ សិស្សក៏អាចរៀនពីអាជីវកម្មដែលមាននៅក្នុងមូលដ្ឋានក្នុងរូបភាពហាត់ការទៅតាមលំនាំដូចខាងក្រោម៖

1. ស្វែងយល់ពីប្រធានបទដែលត្រូវរៀន ដែលអាចជាបញ្ហាសង្គម ឬអាជីពងាយ
2. ស្រង់ព័ត៌មាន និងបទពិសោធពីសហគមន៍លើប្រធានបទដែលត្រូវរៀន
3. វិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា ដើម្បីរកដំណោះស្រាយ ឬធ្វើផែនការអាជីវកម្មចំពោះអាជីពងាយ
4. អភិវឌ្ឍផែនការសកម្មភាពងាយៗ ដែលសិស្សដឹកនាំដោយមានការចូលរួមពីសហគមន៍ ឬធ្វើផែនការអាជីវកម្មរបស់ខ្លួន
5. អនុវត្តផែនការសកម្មភាពនៅតាមសហគមន៍ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ឬចាប់ផ្តើមអនុវត្តផែនការអាជីវកម្មរបស់ខ្លួន
6. ឆ្លុះបញ្ចាំងនិងវាយតម្លៃលើការបង្រៀននិងរៀនលើប្រធានបទ។

## ៧. ការវាយតម្លៃការបង្រៀន និងរៀនបំណិនជីវិត

ការវាយតម្លៃសិស្សក្នុងការរៀនបំណិនជីវិតផ្តោតលើទិដ្ឋភាពបីយ៉ាង៖

1. ការអភិវឌ្ឍចំណេះដឹងដែលជួយសិស្សឱ្យសម្រេចចិត្តបានត្រឹមត្រូវ ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍។
2. ការអភិវឌ្ឍបំណិនបុរេវិជ្ជាជីវៈ ការគ្រប់គ្រងអាជីវកម្មនិងការងារ ព្រមទាំងជំនាញបច្ចេកទេស ដែលជួយឱ្យជីវិតនិងការងាររបស់សិស្សប្រកបដោយជោគជ័យ។
3. ការអភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួន ដែលជួយឱ្យសិស្សទទួលបាននូវសេចក្តីថ្លៃថ្នូរ និងការគោរពពីអ្នកដទៃ និងចូលរួមប្រព្រឹត្តទង្វើល្អសម្រាប់សង្គម។

ការវាយតម្លៃនេះផ្តោតលើការរីកចម្រើនរបស់សិស្សក្នុងការអភិវឌ្ឍចំណេះដឹងជុំវិញខ្លួន បំណិនទូទៅ និងគុណតម្លៃផ្ទាល់ខ្លួន នៅក្នុងអំឡុងនៃការរៀនកម្មវិធីបំណិនជីវិតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- **ផ្នែកចំណេះដឹង** ផ្តោតលើខ្លឹមសារជាក់លាក់ដែលជួយអ្នកសិក្សាឱ្យសម្រេចចិត្តបានត្រឹមត្រូវ ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយក្នុងប្រធានបទសិក្សា។ លក្ខណៈវិនិច្ឆ័យវាយតម្លៃនឹងផ្តោតលើចំណេះដឹងដែលទទួលបាន ការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង និងការប្រើប្រាស់ចំណេះដឹងសម្រាប់គ្រួសារនិងសហគមន៍។
- **ផ្នែកការអភិវឌ្ឍបំណិន** ផ្តោតលើបំណិនដែលសិស្សបានសិក្សាដោយជ្រើសក្នុងចំណោម បំណិនបុរេវិជ្ជាជីវៈ ការគ្រប់គ្រងអាជីវកម្មនិងការងារ និងបច្ចេកទេសទៅតាមប្រធានបទនិងតម្រូវការរបស់សិស្ស។ បំណិនការប្រាស្រ័យទាក់ទង ការកំណត់គោលដៅ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ការធ្វើផែនការនិងចាត់ចែង ការគ្រប់គ្រងពេលវេលា ការគិតបែបពិចារណា ការមានហេតុផល និងការងារជាក្រុម។
- **ផ្នែកប្រតិបត្តិ** សំដៅលើទៅលើការប្រមូលព័ត៌មានពីសហគមន៍ ការរៀបចំផែនការផ្សព្វផ្សាយ ឬផែនការអាជីវកម្ម ការអនុវត្តផែនការ ការឆ្លុះបញ្ចាំង និងវង្វាយតម្លៃ។ ការរៀបចំកិច្ចការ ថែទាំ និងគ្រប់គ្រងផលិតផល។
- **ផ្នែកគុណតម្លៃផ្ទាល់ខ្លួន** គុណតម្លៃដែលសិស្សបានអភិវឌ្ឍតាមរយៈការសិក្សាមេរៀនបំណិនជីវិតមានលក្ខណៈអនុវត្តជាក់ស្តែង ហើយឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ ការឱ្យតម្លៃលើខ្លួនឯង ភាពស្មោះត្រង់ ឥរិយាបថវិជ្ជមាន ការគ្រប់គ្រងកំហឹង ការទទួលខុសត្រូវ។ល។

## ៨. យន្តការគាំទ្រ និងអនុវត្តបំណិនជីវិត

ដើម្បីសម្រេចបាននូវការអនុវត្តក្របខណ្ឌកម្មវិធីសិក្សានេះ ការគាំទ្រនិងការអនុវត្តត្រូវផ្តោតលើយន្តការសំខាន់ៗ ដូចខាងក្រោម៖

### ៨.១. ការពង្រឹងសមត្ថភាពមន្ត្រីអប់រំថ្នាក់ជាតិ

ពង្រឹងសមត្ថភាពមន្ត្រីអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអង្គភាពពាក់ព័ន្ធឱ្យមានចំណេះដឹងច្បាស់លាស់និងស៊ីជម្រៅលើកម្មវិធីសិក្សា មុខវិជ្ជាសិក្សា វិធីសាស្ត្របង្រៀននិងរៀន និងការវាយតម្លៃ។

## ៨.២. ការណែនាំសម្រាប់ការតម្រង់ទិសថ្នាក់ខេត្ត

បង្ហាញពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលកែសម្រួលថ្មី ដើម្បីបង្កើនការយល់ដឹងដល់មន្ត្រីថ្នាក់ខេត្ត និងគាំទ្រដល់ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅតាមមូលដ្ឋាន។

| ថ្នាក់ដឹកនាំមន្ទីរ | ក្រុមការងារថ្នាក់ខេត្ត | ខ្លឹមសារសំខាន់ៗ |
|---|---|---|
| • ប្រធាន/អនុប្រធានមន្ទីរ<br>• ប្រធានការិ. មធ្យមសិក្សា<br>• ប្រធានការិ. អធិការកិច្ច<br>• ប្រធានការិ. យុវជន<br>• ប្រធានការិ. បឋមសិក្សា | • មន្ត្រីការិ. មធ្យមសិក្សា<br>• មន្ត្រីការិ. អធិការកិច្ច<br>• មន្ត្រីការិ. បឋមសិក្សា<br>• គ្រូឧទ្ទេសសាលា/មជ្ឈ.គរុ. | • គោលនយោបាយ បញ្ញត្តិ និងយុទ្ធសាស្ត្រអប់រំបំណិនជីវិត<br>• កម្មវិធីសិក្សាបែបពិគ្រោះយោបល់<br>• លំនាំនៃការបង្រៀននិងរៀន<br>• ការវាយតម្លៃការអប់រំបំណិនជីវិត<br>• ការបង្កើតដៃគូ និងគាំទ្រពីសហគមន៍<br>• ការគាំទ្រដល់ថ្នាក់ស្រុក និងសាលារៀន<br>• ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញការអប់រំបំណិនជីវិត |

## ៨.៣. ការបំប៉នក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ( DTMT ) និងគ្រូបំណិនជីវិត

នាយកសាលាជ្រើសរើសគ្រូដែលមានចំណាប់អារម្មណ៍ និងមានពេលគ្រប់គ្រាន់ក្នុងការបង្រៀនបំណិនជីវិត។ ការសម្រេចបាននូវចង្កោមបំណិនរបស់អាអាស្រ័យលើនាយកសាលា និងគ្រូបង្រៀន។

| ថ្នាក់សាលារៀន | ក្រុមការងារថ្នាក់ស្រុក | ខ្លឹមសារសំខាន់ៗ |
|---|---|---|
| • គ្រូបំណិនជីវិត<br>• នាយកសាលា | • ប្រធានការិ.អយក. ស្រុក<br>• សមាជិក DTMT | • បញ្ញត្តិ និងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន<br>• ការអភិវឌ្ឍកម្មវិធីសិក្សាបែបពិគ្រោះយោបល់<br>• លំនាំនៃការបង្រៀននិងរៀនបំណិនជីវិត (លម្អិត ៦ ដំណាក់កាល)<br>• ការវាយតម្លៃសិស្ស (បំណិនដែលសិស្សអភិវឌ្ឍ)<br>• ការគាំទ្ររបស់សហគមន៍ក្នុងការអប់រំបំណិនជីវិត<br>• ការប្រជុំប្រចាំត្រីមាសពិនិត្យមើលវឌ្ឍនភាព |

## ៨.៤. ការតម្រង់ទិសដល់សាលារៀន និងសហគមន៍

DTMT ត្រូវសហការជាមួយនាយកសាលារៀបចំការតម្រង់ទិសដល់សហគមន៍ ដើម្បីឱ្យសហគមន៍ចូលរួមពេលលេញ។ ការតម្រង់ទិសនេះ ផ្តោតលើខ្លឹមសារដូចខាងក្រោម ព្រមទាំងកំណត់តួនាទីរបស់សហគមន៍ ធនធានពេលវេលា និងអ្នកជំនាញសហគមន៍។ ទន្ទឹមនឹងនេះ DTMT មានតួនាទីសម្របសម្រួលការប្រជុំប្រចាំត្រីមាស ដើម្បីពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងចែករំលែកបទពិសោធនៅក្នុងស្រុករបស់ខ្លួន។

| អ្នកចូលរួម | ខ្លឹមសារសំខាន់ៗ |
|---|---|
| • នាយក/នាយករងសាលា<br>• គណៈកម្មការទ្រទ្រង់សាលា<br>• តំណាងក្រុមប្រឹក្សាឃុំ/សង្កាត់<br>• អ្នកជំនាញក្នុងសហគមន៍ | • បញ្ញត្តិ និងការអប់រំបំណិនជីវិត<br>• ដំណើរការអភិវឌ្ឍកម្មវិធីបំណិនជីវិតបែបពិគ្រោះយោបល់<br>• តួនាទី និងការទទួលខុសត្រូវរបស់សហគមន៍<br>• ភាពជាដៃគូរវាងសាលារៀននិងសហគមន៍ក្នុងការបង្រៀនបំណិនជីវិត (គ្រូជាអ្នកសម្របសម្រួលការរៀនរបស់សិស្ស ប៉ុន្តែសហគន៍អាចចូលរួមជាវាគ្មិន ផ្តល់ឱកាសហាត់ការ ផ្តល់កសិដ្ឋានដើម្បីរៀនសូត្រ។ល។)<br>• ការប្រជុំប្រចាំត្រីមាសរវាងសាលារៀន និងសហគមន៍ ដើម្បីពិនិត្យមើលវឌ្ឍនភាពការអប់រំបំណិនជីវិត។ |

## ៨.៥. ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

រៀបចំការប្រជុំប្រចាំឆ្នាំពិនិត្យមើលវឌ្ឍនភាពការអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅក្នុងខេត្តនីមួយៗ ដោយមានការចូលរួមពីគ្រូឧទ្ទេសថ្នាក់ជាតិ។ កិច្ចប្រជុំនឹងត្រូវផ្តោតលើ៖

១. កម្មវិធីសិក្សាបែបពិគ្រោះយោបល់ការបង្រៀនបំណិនជីវិតតាមសាលារៀន
២. ដំណើរការនៃការបង្រៀន និងរៀន
៣. ការចូលរួមរបស់សហគមន៍ក្នុងការអប់រំបំណិនជីវិត
៤. ការវាយតម្លៃលើបំណិនដែលសិស្សបានអភិវឌ្ឍ។

## ៨.៦. កិច្ចសហប្រតិបត្តិការ

លើកទឹកចិត្តដល់អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការគាំទ្រការអនុវត្តក្របខណ្ឌកម្មវិធីសិក្សា តាមរយៈជាកម្មវិធី ឬគម្រោងផ្សេងៗ។

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា (២០០១) ឯកសារសម្រាប់កម្មវិធីបំណិនជីវិត ភ្នំពេញៈ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៤) គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ ភ្នំពេញៈ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៦ក) កម្មវិធីសិក្សាគោលសម្រាប់អប់រំចំណេះទូទៅ ភ្នំពេញៈក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៦ខ) គោលនយោបាយអប់រំបំណិនជីវិត ភ្នំពេញៈ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១១ក) កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សា ភ្នំពេញៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១១ខ) កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់មធ្យមសិក្សា ភ្នំពេញៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស ភ្នំពេញៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

# ឯកសារដែលបានអភិវឌ្ឍ

**ផ្នែកកសិកម្ម** រួមមាន ការចិញ្ចឹមមាន់ ការចិញ្ចឹមត្រី ការចិញ្ចឹមកង្កែប ការដាំបន្លែសរីរាង្គ ដំណាំស្រូវ ដំណាំសណ្តែកទ្រើង ការបណ្តុះផ្សិតចំបើង សួនជីវៈចម្រុះ ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ (ភាគ១ ភាគ២ និងភាគ៤) ឯកសារជំនួយស្មារតីផ្នែកកសិកម្ម។

**ផ្នែកសិប្បកម្ម** រួមមាន ជំនាញជាងកំបោរ បច្ចេកទេសជំនាងឈើ ឯកសារជំនួយស្មារតីផ្នែករោងជាង។

**ផ្នែកសេវាកម្ម** រួមមាន ដំណាប់ផ្លែឈើ ជំនាញទីផ្សារខ្ញុំ ការគ្រប់គ្រងប្រាក់ ជំនាញជួសជុលកង់ ជំនាញកាត់សក់ ជំនាញកាត់ដេរ វិធីស្រាវជ្រាវក្នុងការធ្វើម្ហូបងាយៗ ឯកសារជំនួយផ្នែកគេហវិទ្យា។

**ផ្នែកសង្គម** រួមមានអនាគតខ្ញុំ ពិភពការងារ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ការយល់ដឹងពីបរិស្ថាន ការយល់ដឹងផ្ទាល់ខ្លួននិងទំនាក់ទំនងសង្គម ទឹកស្អាតនិងអនាម័យផ្ទាល់ខ្លួន ឯកសារអប់រំបំណិនជីវិតស្តីពីបរិស្ថាន និងសុវត្ថិភាពនៃការប្រើប្រាស់ដីធ្លី (សម្រាប់ថ្នាក់ទី៧ ៨ ៩ និងថ្នាក់ទី១០ ដោយគម្រោង អេកូសន)។

**ផ្នែកអនាម័យ និងសុខភាព** ការអប់រំបង្ការជំងឺគ្រុនចាញ់សម្រាប់បឋមសិក្សានិងមធ្យមសិក្សា ការអប់រំសុខភាពអនាម័យនិងអាហារូបត្ថម្ភ ការសង្គ្រោះបឋម ការអប់រំសុខភាពដើម្បីបង្ការទប់ស្កាត់ជង្គូវព្រូនសម្រាប់បឋមសិក្សា ការអប់រំសុខភាពភ្នែកសម្រាប់បឋមសិក្សា សុខភាពបន្តពូជនិងសុខភាពផ្លូវភេទសម្រាប់បឋមសិក្សា(៥&៦) សម្រាប់មធ្យមសិក្សាបឋមភូមិ(៧&៨) និងសម្រាប់មធ្យមសិក្សាទុតិយភូមិ(១០&១១)។

# សន្ទានុក្រម

**ទំនុកចិត្តលើខ្លួនឯង៖** ការមានទំនុកចិត្តលើខ្លួនឯង មានន័យថាជាការយល់ថាខ្លួនអ្នកមានតម្លៃ និង ជឿថាអ្នកមានតម្លៃសមទទួលបានជោគជ័យធំៗ។ នៅពេលកុមារមានទំនុកចិត្តលើខ្លួនឯង ពួកគេអាចធ្វើការសម្រេចចិត្តល្អអំពីសាលា និង ទំនាក់ទំនងរបស់ពួកគេ។

**ការសម្តែងនិងការគ្រប់គ្រងមនោសញ្ចេតនា៖** ការសម្តែងមនោសញ្ចេតនារបស់អ្នក មានន័យថាអ្នកអាចចែករំលែកអារម្មណ៍អ្នកជាមួយអ្នកដទៃ។ នៅពេលអ្នកសម្តែងមនោសញ្ចេតនារបស់អ្នក អ្នកអាចកំណត់អារម្មណ៍របស់អ្នក និង យល់ថាតើវាមានឥទ្ធិពលលើគំនិតនិងឥរិយាបថរបស់អ្នកយ៉ាងដូចម្តេច។ កុមារម្នាក់ដែលអាចសម្តែងនិងគ្រប់គ្រងមនោសញ្ចេតនា អាចឆ្លងកាត់ពិសោធន៍ជាបញ្ហាប្រឈមនិងលំបាកយ៉ាងរឹងប៉ឹង។

**ការយល់ចិត្ត៖** ការយល់ចិត្ត គឺជាសមត្ថភាពដឹងពីមនោសញ្ចេតនារបស់អ្នកដទៃ។ នៅពេលអ្នកមានការយល់ចិត្ត អ្នកអាចស្រមៃអំពីអារម្មណ៍ដែលអ្នកណាម្នាក់កំពុងមាន ដើម្បីអ្នកអាចធ្វើជាអ្នកស្តាប់ប្រកបដោយចិត្តមេត្តា។ នៅពេលកុមារម្នាក់មានការយល់ចិត្ត នាងទំនងជានឹងមិនបង្ហាញឥរិយាបថគ្មានមេត្តាចំពោះអ្នកដទៃទេ ដោយសារនាងមិនចង់ធ្វើឱ្យអ្នកណាម្នាក់មានទុក្ខព្រួយ។

**ការគ្រប់គ្រងខ្លួនឯង៖** ការមានការគ្រប់គ្រងខ្លួនឯង មានន័យថាអ្នកអាចគ្រប់គ្រងមនោសញ្ចេតនារបស់អ្នក និង មានឥរិយាបថសមស្របនៅក្នុងគ្រប់ស្ថានភាព ទាំងនោះសាលា ទាំងនៅក្នុងគ្រួសារ។ នៅពេលអ្នកអាចគ្រប់គ្រងឥរិយាបថរបស់អ្នកយ៉ាងរឹងប៉ឹង អ្នកកំពុងអនុវត្តការគ្រប់គ្រងខ្លួនឯង។

**ការត្រិះរិះពិចារណា៖** ការប្រើបំណិនត្រិះរិះពិចារណា ជួយឱ្យអ្នកវាយតម្លៃព័ត៌មាន និង ពិនិត្យមើលបញ្ហាចេញពីទស្សនៈជាច្រើន។ កុមារម្នាក់ដែលត្រិះរិះពិចារ នឹងដោះស្រាយបញ្ហាដោយប្រើតក្កវិជ្ជា យល់មុខវិជ្ជាថ្មីនៅសាលា និង ធ្វើការសម្រេចចិត្តបានល្អអំពីជីវិតរបស់ខ្លួន។ វាក៏ជួយផងដែរឱ្យកុមារីយល់បានកាន់តែប្រសើរឡើងអំពីយោបល់និងអារម្មណ៍របស់មិត្តភក្តិ គ្រូ និង គ្រួសារពួកគេ។

**ការធ្វើសេចក្តីសម្រេចចិត្ត៖** ការមានបំណិនធ្វើសេចក្តីសម្រេចចិត្តល្អ មានន័យថាអ្នកគិតយ៉ាងមធ្យ័តអំពីលទ្ធផលដែលអាចមានទាំងអស់នៃការសម្រេចចិត្តមួយ។ នៅពេលកុមារម្នាក់មានបំណិនធ្វើសេចក្តីសម្រេចចិត្តល្អ នាងក៏អាចធ្វើការសម្រេចចិត្តដ៏វាងវៃផងដែរអំពីសាលា មិត្តភក្តិ និង ការងារដែលនឹងនាំមកនូវជោគជ័យដល់រូបនាង។

**ការស៊ូទ្រាំ៖** ការមានការស៊ូទ្រាំ មានន័យថាអ្នកនៅតែព្យាយាមធ្វើអ្វីមួយ សូម្បីតែនៅពេលដែលមានការលំបាក ហើយអ្នកមិនទទួលបានជោគជ័យយ៉ាងលឿនឬយ៉ាងងាយក្តី។ កុមារដែលមានការស៊ូទ្រាំតាំងចិត្តចំពោះការសម្រេចគោលដៅ ការរៀនអ្វីដែលថ្មី និង ការឆ្លងកាត់ពេលវេលាលំបាកនៅក្នុងសាលា និង នៅក្នុងជីវិត។

**ការប្រាស្រ័យទាក់ទង៖** ការប្រាស្រ័យទាក់ទងល្អ មានន័យថាជាការនិយាយ និង ការស្តាប់ប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដទៃ។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពរវាងបុគ្គល កែលម្អទំនាក់ទំនង។ ការប្រាស្រ័យទាក់ទង និង ការស្តាប់បានល្អ ជួយកុមារឱ្យដោះស្រាយបញ្ហាក្នុងលក្ខណៈវិជ្ជមាន កែលម្អមិត្តភាព និង ទទួលបានជោគជ័យនៅសាលា និង នៅក្នុងអាជីពពួកគេ។

**ការដោះស្រាយបញ្ហាក្នុងលក្ខណៈច្នៃប្រឌិត:** ការដោះស្រាយបញ្ហាក្នុងលក្ខណៈច្នៃប្រឌិត មានន័យថានៅពេលអ្នកមានបញ្ហាមួយ អ្នករកឃើញដំណោះស្រាយមួយ។ កុមារអាចប្រើបំណិនដោះស្រាយបញ្ហាក្នុងលក្ខណៈច្នៃប្រឌិត នៅពេលពួកគេជួបប្រទះបញ្ហានៅសាលា ជាមួយមិត្តភក្តិ និង នៅក្នុងគ្រួសារ។

**ការកសាងទំនាក់ទំនង:** នៅពេលអ្នកមានបំណិនកសាងទំនាក់ទំនង អ្នកអាចរក្សាទំនាក់ទំនងមានស្រាប់របស់អ្នក និង កសាងមិត្តភាពថ្មីដែលមានលក្ខណៈវិជ្ជមាន និង រឹងប៉ឹង។ នៅពេលកុមាររៀនកសាងទំនាក់ទំនងល្អត្រឹមត្រូវ ពួកគេកំពុងរៀនរបៀបផ្តល់តម្លៃដល់ និង គោរពខ្លួនឯង និង មិត្តភក្តិថ្មីរបស់ពួកគេ អនុវត្តបំណិនប្រាស្រ័យទាក់ទង និង កសាងការយល់ចិត្ត និង ទំនុកចិត្តលើខ្លួនឯង។

**ការយល់ចិត្តអ្នកដទៃ:** បង្ហាញលទ្ធភាពរក្សាចំណាប់អារម្មណ៍ជ្រាលជ្រៅលើកង្វល់ និង អារម្មណ៍របស់អ្នកដទៃ។ មានចិត្តចង់ជួយមនុស្ស។

**ការយល់ស៊ីជម្រៅអំពីអ្នកដទៃ:** បង្ហាញការយល់អំពីអ្វីដែលធ្វើឱ្យមនុស្សធ្វើអ្វីដែលពួកគេធ្វើ និង ការអត់ឱនចំពោះសកម្មភាពរបស់អ្នកដទៃ។ ពូកែកាត់យល់អំពីអារម្មណ៍របស់អ្នកដទៃ។

**ការគោរព:** សំដៅដល់ការបង្ហាញនូវការគិតគូរដល់អារម្មណ៍ តម្រូវការ គំនិត បំណងប្រាថ្នា និង ការចង់បានរបស់អ្នកដទៃ (រួមទាំងវប្បធម៌ និង ពូជសាសន៍ដទៃ)។

**ការនិយាយ/ការបង្ហាញ:** បង្ហាញព័ត៌មានយ៉ាងច្បាស់ និង យ៉ាងមានជំនឿជាក់ចំពោះបុគ្គលឬក្រុមដទៃ។ រក្សាទំនាក់ទំនងក្រសែភ្នែកបានល្អ និង ទាក់ទាញការយកចិត្តទុកដាក់របស់អ្នកស្តាប់ ឬ បុគ្គល។

**ការស្តាប់សកម្ម:** ផ្តល់ការយកចិត្តទុកដាក់ទាំងស្រុងចំពោះអ្វីដែលអ្នកដទៃកំពុងនិយាយ ចំណាយពេលដើម្បីយល់គំនិតដែលបានលើក សួរសំណួរតាមការចាំបាច់ និង មិនលូកមាត់កាត់ដោយមិនសមស្របទេ។

**ការសន្ទនា:** និយាយយ៉ាងច្បាស់ និង ស្តាប់យ៉ាងប្រុងប្រយ័ត្ន។ ស្តាប់អ្នកដទៃ មិនមែនស្តាប់ខ្លួនឯងទេ។ សុំការបំភ្លឺនៅពេលណាចាំបាច់ និង ស្វែងយល់យ៉ាងសមស្របនូវភាសាកាយវិការ។

**ការបញ្ចុះបញ្ចូល:** បង្ហាញលទ្ធភាពមានឥទ្ធិពលលើជំនឿនិងសកម្មភាពរបស់អ្នកដទៃ។ បង្ហាញលទ្ធភាពទទួលបានកិច្ចសហប្រតិបត្តិការនិងការគាំទ្ររបស់អ្នកដទៃចំពោះគំនិតឬសកម្មភាព។

**សមាជិកភាពក្រុម:** ធ្វើការយ៉ាងងាយជាមួយក្រុមមនុស្ស និង បង្ហាញភក្តីភាព និង ការប្តេជ្ញាចំពោះគោលបំណងរបស់ក្រុម។ យកចិត្តទុកដាក់លើទស្សនៈរបស់សមាជិកម្នាក់ៗស្មើៗគ្នា។

**ការចូលរួមក្នុងក្រុម:** បង្ហាញទស្សនៈនិងយោបល់ជាចំហនៅក្នុងក្រុម។ បង្ហាញឆន្ទៈទទួលយកភារកិច្ចនិងការទទួលខុសត្រូវ ដែលសមស្របនឹងបទពិសោធន៍របស់ខ្លួន។

**ភាពជាអ្នកដឹកនាំ:** បង្ហាញលទ្ធភាពពន្យល់ចក្ខុវិស័យឬគោលដៅមួយជូនអ្នកដទៃ និង ដឹកនាំពួកគេឆ្ពោះទៅសម្រេចចក្ខុវិស័យឬគោលដៅនោះ។ ជំរុញឱ្យមានសកម្មភាព និង លទ្ធផល និង កៀរគរបានការគាំទ្រនិងជំនួយពីអ្នកដទៃ។

**ការធ្វើផែនការ/ការចាត់ចែង:** បង្កើតគោលដៅច្បាស់លាស់ កំណត់ និង រកធនធាន (ឧទាហរណ៍ ពេលវេលា មនុស្ស សម្ភារ) ដែលចាំបាច់ដើម្បីសម្រេចគោលដៅ និង កំណត់ពេលវេលាការងារដើម្បីបញ្ចប់ការងារឱ្យបានទាន់ពេល។

**ការគ្រប់គ្រងពេលៈ** ចំណាយពេលដើម្បីរៀបចំព្រឹត្តិការណ៍និងភារកិច្ចយ៉ាងប្រុងប្រយ័ត្ន ដើម្បីប្រើពេលវេលាយ៉ាងមានប្រសិទ្ធភាព។ ប្រើសៀវភៅកំណត់ហេតុ/សៀវភៅរៀបចំផែនការដើម្បីធានាឱ្យបានថាភារកិច្ចត្រូវបានធ្វើ។

**បំណិនជាក់ស្តែងៈ** ប្រើគ្រឿងបរិក្ខារ ឧបករណ៍ ឬ បច្ចេកវិទ្យាយ៉ាងមានប្រសិទ្ធភាព។ អនុវត្តតាមការណែនាំបានយ៉ាងងាយ និង បង្ហាញឆន្ទៈប្រើឧបករណ៍ឬបច្ចេកទេសអ្វីក៏ដោយដែលចាំបាច់។

**បំណិនកុំព្យូទ័រៈ** ប្រើកុំព្យូទ័រប្រកបដោយជំនឿជាក់ដើម្បីសរសេរឯកសារ មើលអ៊ីនធឺណេត ឬ ប្រើកម្មវិធីអ៊ីម៉េល។ អាចរក្សា (save ) ឯកសារ រកឯកសារយ៉ាងមានប្រសិទ្ធភាព និង បោះពុម្ពឯកសារ។

**ការដោះស្រាយបញ្ហាៈ** បង្ហាញចំណាប់អារម្មណ៍លើការរិះរកមូលហេតុនៃបញ្ហា ស្វែងរកនិងជ្រើសរើសយកដំណោះស្រាយមានប្រសិទ្ធភាព និង ធ្វើសកម្មភាពចាំបាច់ទាំងឡាយដើម្បីដោះស្រាយបញ្ហាទាំងនោះ។

**ការយល់ដឹងអំពីធុរកិច្ចៈ** បង្ហាញការយល់អំពីសកម្មភាពធុរកិច្ចចម្បងរបស់ក្រុមហ៊ុន/ស្ថាប័ន។ ចេះយល់ពីឱកាសធុរកិច្ចដែលមាន និង គូប្រកួតប្រជែងចម្បង។

**ការយកចិត្តទុកដាក់លើអតិថិជនៈ** បង្ហាញការយល់ និង កង្វល់ចំពោះសេចក្តីត្រូវការរបស់អតិថិជន ជួយ និង រាក់ទាក់ចំពោះអតិថិជន និង ដោះស្រាយយ៉ាងមានប្រសិទ្ធភាពនូវសំណួរ ឬ ការតវ៉ាដែលពួកគេអាចមាន។

**បំណិនសិក្សាៈ** ខិតខំ និង ឆ្លៀតរៀន។ បង្ហាញចំណាប់អារម្មណ៍លើការរៀនដោយខ្លួនឯង និង ការអភិវឌ្ឍផ្ទាល់ខ្លួន។ សុំយោបល់ត្រឡប់ដើម្បីកែលម្អការយល់។

**ការសម្របទៅនឹងការប្រែប្រួលៈ** សម្របទៅនឹងបញ្ហាប្រឈមថ្មីៗយ៉ាងងាយ និង បង្ហាញភាពបើកទូលាយចំពោះវិធីថ្មីៗនៃការធ្វើអ្វីមួយ។ មានប្រសិទ្ធភាពលើការផ្លាស់ប្តូរផែនការ ឬ សកម្មភាព ដើម្បីឆ្លើយតបទៅនឹងស្ថានភាពប្រែប្រួល។

**ការកំណត់គោលដៅៈ** បង្ហាញលទ្ធភាពធ្វើការសម្រេចចិត្តអំពីអ្វីដែលចង់បាន និង កំណត់ពេលដែលត្រូវសម្រេចកិច្ចការនោះ។ ប្រកាន់ខ្ជាប់នូវគោលដៅ និង ដោះស្រាយបញ្ហាលំបាកនានាក្នុងលក្ខណៈប្រាកដនិយម។

**គំនិតផ្តួចផ្តើមៈ** បង្ហាញលទ្ធភាពផ្តួចផ្តើមគំនិតនៅក្នុងស្ថានភាពមួយ។ បង្ហាញទំនោររិះរកឱកាសដើម្បីធ្វើការសម្រេចចិត្ត ឬ ជះឥទ្ធិពលលើព្រឹត្តិការណ៍។

**ឯករាជ្យភាពៈ** អាចធ្វើកិច្ចការប្រកបដោយប្រសិទ្ធភាព ដោយមានជំនួយឬការយល់ព្រមអប្បបរមា ឬ ដោយគ្មានការត្រួតពិនិត្យផ្ទាល់។

**ការជំរុញទឹកចិត្តៈ** បង្ហាញការជំរុញដើម្បីជោគជ័យ និង បំពេញភារកិច្ចបានល្អ។ បង្ហាញទំនុកចិត្តលើលទ្ធភាព និង រំពឹងទទួលបានជោគជ័យលើគ្រប់ភារកិច្ចដែលបានឯកភាព។

**ភាពអាចពឹងពាក់បានៈ** អាចទុកចិត្តបាន ទទួលខុសត្រូវ និង ពឹងពាក់បានក្នុងការបំពេញភារកិច្ច។ ពិនិត្យមើលការងារយ៉ាងមធ្យ័តដើម្បីធានាឱ្យបានថារាល់ចំណុចលម្អិតទាំងអស់ត្រូវបានពិចារណា។

**វិជ្ជាជីវៈនិយមៈ** រក្សាភាពនឹងនរ និង គ្រប់គ្រងខ្លួនឯង ក្នុងស្ថានភាពថប់អារម្មណ៍។ ខិតខំធ្វើការដើម្បីសម្រេចបានផលប្រយោជន៍ប្រសើរបំផុតរបស់ស្ថាប័ន នៅគ្រប់ពេលទាំងអស់ និង មានសម្លៀកបំពាក់សមរម្យ។